**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Nov-2014, 09:31
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

**នៅចំពោះមុខ៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម C.N. JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

Original EN:

មុំច សុវណ្ណារី
ស៊ិន សុវ៉ាន
សំ សុគង់
វើន ពៅ
ទី ស្រីនណា
Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Julien RIVET
Nushin SARKARATI
Beini YE

**<u>ផ្ញើជូន៖</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ជា លាង
Nicholas KOUMJIAN
យ៉េត ចរិយា
William SMITH

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន
នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ
Victor KOPPE

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

## I. សេចក្តីផ្តើម

1. យោងតាមសំណើសុំនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមប្រកាសអំពីបំណងរបស់ខ្លួនចង់ធ្វើការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ ដែលគ្រោងនឹងដាក់នាពេលមុខដោយមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ("មេធាវីការពារក្តី") និងសហព្រះរាជអាជ្ញា។ ការបដិសេធមិនឱ្យធ្វើការឆ្លើយតបនេះនឹងធ្វើឱ្យប៉ះពាល់យ៉ាងធំធេងចំពោះផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយក្រុម នៅក្នុងការប្តឹងសាទុក្ខ ព្រមទាំងនៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។

2. ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៃកិច្ចដំណើរការនីតិវិធីដែលមានសិទ្ធិដោយឡែកមួយ។ សហមេធាវីនាំមុខមានបំណងឆ្លើយតបទៅនឹង *ក្នុងចំណោមនោះ* កំហុសអង្គហេតុ និងអង្គច្បាប់ដូចដែលបានចោទប្រកាន់ ទាក់ទងនឹងភស្តុតាងដែលបានផ្តល់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណី។ លើសពីនេះទៀត សហមេធាវីនាំមុខសូមរក្សាសិទ្ធិក្នុងការដាក់សារណាបញ្ជាក់បំភ្លឺអំពីជំហររបស់ខ្លួនពាក់ព័ន្ធនឹងសារណាបណ្តឹងសាទុក្ខដែលនឹងដាក់ដោយសហព្រះរាជអាជ្ញា។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សាលក្រម") ដោយបានសម្រេចថា ជនជាប់ចោទទាំងពីរមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលរួមមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត ហើយបានកាត់ទោសជនជាប់ចោទម្នាក់ៗឱ្យជាប់ពន្ធនាគារអស់មួយជីវិត[1]។

4. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន ("សហជនជាប់ចោទ") ក៏បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួន ប្រឆាំងនឹងសាលក្រមដោយបានលើកឡើងអំពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុនៅក្នុងសាលក្រមដែលទាក់ទង *ក្នុងចំណោមនោះគឺ*

[1] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

នីត្យានុកូលភាព និងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ការប្រើប្រាស់ភ័ស្តុតាង និងការសម្លាប់ដោយចេតនាលើជនស៊ីវិលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[2]។

5. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាក៏បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេប្រឆាំងនឹងសាលក្រម ដោយបានគូសបញ្ជាក់អំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលពួកគេស្នើសុំលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[3]។ ពួកគេបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការសម្រេចមិនពិចារណាអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ក្នុងខណៈពេលដែលសម្រេចអំពីពិរុទ្ធភាពរបស់សហជនជាប់ចោទ[4]។

6. នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្តី នួន ជា បានដាក់សំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម[5] ដោយក្រោយមកមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើសុំស្រដៀងគ្នានេះដែរនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤[6]។ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមទៅនឹងសំណើសុំទាំងពីរនេះ[7] ដែលជនជាប់ចោទម្នាក់ៗបានដាក់ការឆ្លើយតបមកវិញដោយឡែកៗពីគ្នានៅថ្ងៃទី ២០ និងថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤[8]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល

---

[2] *សូមមើល* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន")។

[3] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")។

[4] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦-៨។

[5] សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F6 ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៤។

[6] ការស្នើសុំជាបន្ទាន់របស់លោក ខៀវ សំផន សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៅក្នុងសារណាបណ្តឹងសាទុក្ខ ឯកសារ F7 ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤។

[7] ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប ឯកសារ F7/1 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤។

[8] ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាបន្ថែម សម្រាប់បណ្តឹងសាទុក្ខ ឯកសារ F7/1/1 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤។ ចម្លើយ និងចម្លើយតបរបស់ក្រុមមេធាវីការពារក្តីលោក

បានយល់ព្រមមួយផ្នែកតាមសំណើរបស់សហជនជាប់ចោទសុំពន្យាររយៈពេលដាក់សារណា បណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួន[9]។

7. នួន ជា និង ខៀវ សំផន តម្រូវឱ្យដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួនយ៉ាងយូរបំផុត ត្រឹមថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ដោយឡែកសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវដាក់នៅត្រឹមថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤[10]។ លើសពីនេះ អង្គជំនុំជម្រះនេះបានបង្គាប់ឱ្យ សហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមយ៉ាងយូរបំផុតត្រឹមរយៈពេល ៣០ ថ្ងៃ ក្រោយពីថ្ងៃ ជូនដំណឹងអំពីសំណៅភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន គិតចាប់ ថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខណាមួយចុងក្រោយគេ[11]។

## III. ការពិភាក្សា

### ក. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិឆ្លើយតបទៅនឹងកំហុសនានាដែលបានលើកឡើងដោយ មេធាវីការពារក្តីនៅក្នុងបណ្តឹងសាទុក្ខ

8. វិធាន ១០៥ នៃវិធានផ្ទៃក្នុងចែងថា ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹង [តែ] សេចក្តីសម្រេចស្តីពីសំណងប៉ុណ្ណោះ។ នៅពេលដែលសហព្រះរាជអាជ្ញា បានធ្វើបណ្តឹងសាទុក្ខរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រម[12]។ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមាន សិទ្ធិតិចតួចក្នុងការធ្វើបណ្តឹងសាទុក្ខក៏ដោយ ក៏ពុំមានការរិតត្បិតសិទ្ធិមិនឱ្យឆ្លើយតបទៅនឹង សារណាបណ្តឹងសាទុក្ខដែលភាគីនីមួយៗដាក់នៅក្នុងដំណើរការនៃការជំនុំជម្រះឡើយ។

9. គោលការណ៍ជាសារវ័ន្តនៅ អ.វ.ត.ក គឺថាត្រូវធានាថា សិទ្ធិរបស់ជនរងគ្រោះត្រូវបានគោរព *នៅ ទូទាំង* កិច្ចដំណើរការនីតិវិធី[13]។ ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង ព្រមទាំងសេចក្តីណែនាំអនុវត្តជា

---

ខៀវ សំផន ទៅនឹង "ចម្លើយសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និង ពេលវេលាកំណត់សម្រាប់ធ្វើសារណាតប" ឯកសារ F7/1/2 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤។

[9] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប" ឯកសារ F9 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤")។

[10] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២៣។

[11] *ដូចខាងលើ* កថាខណ្ឌ ២៣។

[12] វិធាន ១០៥(១)(គ)នៃវិធានផ្ទៃក្នុង។

[13] វិធានផ្ទៃក្នុង វិធាន ២១(ក)(គូសបញ្ជាក់បន្ថែម)។

ធរមាន តម្រូវឲ្យបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍មិនត្រឹមតែរបស់ជនសង្ស័យ ជនជាប់ចោទ ជនត្រូវចោទប៉ុណ្ណោះនោះទេ ប៉ុន្តែរបស់ជនរងគ្រោះផងដែរ[14]។ ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺជាជនរងគ្រោះដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ[15]។

10. សំខាន់បំផុតនោះ ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៃកិច្ចដំណើរការនីតិវិធីដូចជនជាប់ចោទ និងសហព្រះរាជអាជ្ញាដូចគ្នា[16] ហើយ អ.វ.ត.ក មានកាតព្វកិច្ចត្រូវរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី[17]។ នៅក្នុងដំណាក់កាលនេះ ទាំងសហព្រះរាជអាជ្ញា ទាំងសហជនជាប់ចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួន ដែលនឹងប៉ះពាល់ដល់សិទ្ធិរបស់ភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ព្រមទាំងអាចមានផលប៉ះពាល់លើសំណុំរឿង ០០២/០២ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលវិនិច្ឆ័យសម្រេចនោះ។

11. តួនាទីចម្បងមួយរបស់សហមេធាវីនាំមុខគឺត្រូវតំណាងផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយក្រុម "នៅក្នុងអំឡុងពេលនៃដំណាក់កាលជំនុំជម្រះ និងដំណាក់កាលក្រោយៗ"[18]។ ទោះបីជាវិធាន ១២*ស្ទួនពីរ*(៣) ស្តីពីការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងត្រូវបានកម្រិតត្រឹមការធ្វើជាតំណាងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះក៏ដោយ ក៏បទប្បញ្ញត្តិនេះបានគូសបញ្ជាក់អំពីភាពចាំបាច់ដែលតម្រូវឲ្យសហមេធាវីនាំមុខធានានូវការធ្វើជាតំណាងប្រកបដោយប្រសិទ្ធភាពឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលនៃដំណាក់កាលជំនុំជម្រះ និង*ដំណាក់កាលក្រោយៗ*[19]។

12. ជាការពិត លើកលែងតែមានការហាមឃាត់ច្បាស់លាស់នៅក្នុងវិធាន ១០៥ នៃវិធានផ្ទៃក្នុង សកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលទាំងការចូលរួមនៅក្នុង "ដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តិការរបស់ អ.វ.ត.ក" [20] ដែល

---

[14] វិធានផ្ទៃក្នុង វិធាន ២១។

[15] *ដូចខាងលើ* ទំព័រ ៨០ "ដើមបណ្តឹងរដ្ឋប្បវេណី"។

[16] *ដូចខាងលើ* ទំព័រ ៨១ "ភាគី"។

[17] *ដូចខាងលើ* វិធាន ២១(ក)នៃវិធានផ្ទៃក្នុង។

[18] *ដូចខាងលើ* វិធាន ១២*ស្ទួនពីរ*(៥)(ខ)នៃវិធានផ្ទៃក្នុង។

[19] *សូមមើល ដូចខាងលើ* វិធាន ១២*ស្ទួនពីរ*(១) វិធាន ១២*ស្ទួនពីរ*(៥)(ខ)នៃវិធានផ្ទៃក្នុង(គូសបញ្ជាក់បន្ថែម)។

[20] *ដូចខាងលើ* វិធាន ២៣(១)(ក)នៃវិធានផ្ទៃក្នុង។

នៅពេលអានផ្គួបជាមួយនឹងមាត្រា ៣៦ *ថ្មី* នៃច្បាប់ អ.វ.ត.ក គ្របដណ្តប់រហូតដល់បណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ[21]។ សហមេធាវីនាំមុខបានសន្និដ្ឋានថា ក្នុងករណីមិនមានការហាមឃាត់ណាមួយច្បាស់លាស់នោះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល បាន។

13. ក្នុងចំណោមមូលដ្ឋាននៃបណ្តឹងសាទុក្ខទាំង ២២៣ មូលដ្ឋាន សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា បានរៀបរាប់អំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខប្រហែលជាចំនួន ៨០ មូលដ្ឋាន ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងភស្តុតាងជាច្រើនយ៉ាងដែលផ្តល់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណី។ មូលដ្ឋានទាំងនេះ *ក្នុងចំណោមនោះមាន* ការសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី[22] កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី[23] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[24] សក្ខីកម្មរបស់ជនរងគ្រោះអំពីផលប៉ះពាល់លើរូបគាត់[25] កំណត់ហេតុសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[26] និងបណ្តឹងរបស់ជនរងគ្រោះ[27]។

---

[21] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ មាត្រា ៣៦*ថ្មី*។

[22] មូលដ្ឋានទី ៤៨ (Denise Affonco ឯកសារ D22/36); មូលដ្ឋានទី ៤៩, ១៣៤, ១៧០ (ពិន យ៉ាថៃ ឯកសារ D22/3649); មូលដ្ឋានទី ៧៨ (យឹម សុវណ្ណ ឯកសារ D22/109); មូលដ្ឋានទី ៨០ (មុម សំអឿន ឯកសារ D22/11); មូលដ្ឋានទី ៨១ (ជុំ សុខា ឯកសារ D22/110); មូលដ្ឋានទី ១២០ (ឡាយ បូនី ឯកសារ D22/111); មូលដ្ឋានទី ១១៥, ១៦១ (ពេជ ស្រីផល ឯកសារ D22/209); មូលដ្ឋានទី ១៦៩ (ទឹង សុខា ឯកសារ D22/3286)។

[23] មូលដ្ឋានទី ៥០ (ខឹម ណារ៉េត ឯកសារ D22/92); មូលដ្ឋានទី ៥១ (សុត សែម ឯកសារ D22/106); មូលដ្ឋានទី ៥២, ១១១ (ស៊ាង ចាន់ ឯកសារ D22/121); មូលដ្ឋានទី ៥៣ (ខៀវ ហន ឯកសារ D22/65); មូលដ្ឋានទី ៩៩ (យិន សុខ ឯកសារ D22/78); មូលដ្ឋានទី ១២៧ (ជុំ សុខា ឯកសារ D22/110); មូលដ្ឋានទី ១៥៨ (គង់ វ៉ាច ឯកសារ D22/131)។

[24] មូលដ្ឋានទី ៥៥ (សុត សែម ឯកសារ D22/106); មូលដ្ឋានទី ៥៦ (ប៊ុក សាឯម ឯកសារ D22/247); មូលដ្ឋានទី ៥៧ (សួង ឃិត ឯកសារ D22/309); មូលដ្ឋានទី ៥៨ (មា ឈិន ឯកសារ D22/39); មូលដ្ឋានទី ៥៩ (សែន សុផុន ឯកសារ D22/1232); មូលដ្ឋានទី ៦០ (ដៃ យ៉ឺន ឯកសារ D22/1242); មូលដ្ឋានទី ៦១, ៩០, ១០៥ (ប៉ាល់ រតនៈ ឯកសារ D22/1341); មូលដ្ឋានទី ៦២ (យ៉ាន ញ៉ ឯកសារ D22/2751); មូលដ្ឋានទី ៦៤ (មាស មុត ឯកសារ D22/161); មូលដ្ឋានទី ៦៥, ១២៩ (បេង ហឿន ឯកសារ D22/222); មូលដ្ឋានទី ៦៨ (ខឹម ណារ៉េត ឯកសារ D22/92); មូលដ្ឋានទី ៧០ (ហ៊ុំ ប៊ូណាត់ ឯកសារ D22/350); មូលដ្ឋានទី ៨៣ (មាស សារ៉ាន់ ឯកសារ D22/118); មូលដ្ឋានទី ៨៤ (ម៉ម ផៃបួន ឯកសារ D22/1968); មូលដ្ឋានទី ៨៥ (គង់ ណារិន ឯកសារ D22/524); មូលដ្ឋានទី ៨៩ (ភួង ផល្លា ឯកសារ D22/345); មូលដ្ឋានទី ៩១, ១៤១ (លី វៀម ឯកសារ D22/2690); មូលដ្ឋានទី ៩៥, ១៤២ (សាម ផា ឯកសារ D22/2953); មូលដ្ឋានទី ៩៦ (សែម វីរៈ ឯកសារ D22/35);

14. ការតវ៉ានេះបន្ថែមទៅលើការតវ៉ាជាទូទៅរបស់ពួកគេចំពោះការសំអាងដោយមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងរបស់ជនរងគ្រោះ ខណៈពេលធ្វើការវាយតម្លៃដោយមិនសមស្រប ឬ មិនត្រឹមត្រូវលើតម្លៃនៃភស្តុតាងរបស់វា[28]។

15. ក្នុងចំណោមកំហុសដូចដែលបានអះអាងទាំងនេះ មូលដ្ឋានទី ៣៤ ទាក់ទងដោយផ្ទាល់នឹងដើមបណ្តឹងរដ្ឋប្បវេណីដោយសារវាទាក់ទងនឹងភាពអាចទទួលយកបាន និងតម្លៃនៃភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឲ្យលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី[29]។ យោងតាមមូលដ្ឋាននេះ ពួកគេក៏បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានផ្អែកលើសក្ខីកម្មរបស់ជនរងគ្រោះអំពីផលប៉ះពាល់លើរូបគាត់
ក្នុងការកំណត់អំពីការពិតនៃមាតិការនៅក្នុងសាលក្រមទាំងមូល។

16. មេធាវីការពារក្តី នួន ជា ក៏បានចោទប្រកាន់អំពីកំហុសទាក់ទងនឹងនីត្យានុកូលភាព និងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីផងដែរនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ *ក្នុងចំណោមនោះមាន* សិទ្ធិរបស់ នួន ជា ក្នុងការតទល់នឹងភស្តុតាងប្រឆាំងនឹងគាត់[30] ដែលក្នុងនោះរួមមានទាំង កំណត់

---

មូលដ្ឋានទី ១០៣ (អ៊ឹម គ្រោះ ឯកសារ D22/1239); មូលដ្ឋានទី ១០៤ (ប៊ុត សូត្រ ឯកសារ D22/1240); មូលដ្ឋានទី ១១២ (សូ សារី ឯកសារ D22/2499); មូលដ្ឋានទី ១១៨ (រូ រ៉េន ឯកសារ D22/129); មូលដ្ឋានទី ១២១ (ឈរ ដាណា ឯកសារ D22/2); មូលដ្ឋានទី ១៣៨ (ផាត់ ហន ឯកសារ D22/343); មូលដ្ឋានទី ១៤៣, ១៥២ (សុត ណារី ឯកសារ D22/2090); មូលដ្ឋានទី ១៤៧ (តូច មុនិន្ទ ឯកសារ D22/16); មូលដ្ឋានទី ១៥៨ (គង់ វ៉ាច ឯកសារ D22/131); មូលដ្ឋានទី ១៥៩ (សាន មុំ ឯកសារ D22/2800); មូលដ្ឋានទី ១៦៧ (ឌី រឿន ឯកសារ D22/2068)។

[25] មូលដ្ឋានទី ៧៧ (ឆេង អេងលី); មូលដ្ឋានទី ៧៩ (ធុច ផាន់ដារ៉ា-ស ឯកសារ D22/189); មូលដ្ឋានទី ១៣៣ (សេង ស៊ីវុត្ថា ឯកសារ D22/3804); មូលដ្ឋានទី ១៥៦ (បេ សុផានី); មូលដ្ឋានទី ១៦០ (ចាន់ សុជាតិ ឯកសារ D22/3858); មូលដ្ឋានទី ១៦២ (អូន ផល្លី)។

[26] មូលដ្ឋានទី ១០២ (ខាត់ ខេ); មូលដ្ឋានទី ១៣៩ (ឈឹម មន)។

[27] មូលដ្ឋានទី ៦៣ (អៀម ទៀង); មូលដ្ឋានទី ៧១ (ភួង មុំ); មូលដ្ឋានទី ៧២, ៩៤ (ហេនរី ស៊ុន); មូលដ្ឋានទី ៩២, ១២៨ (ទៀង សុខុម); មូលដ្ឋានទី ៩៣ (ជូ គឹមឡុន); មូលដ្ឋានទី ១០៦ (ព្រុំ សុខា); មូលដ្ឋានទី ១០៧ (ម៉ី ណារី); មូលដ្ឋានទី ១១៣ (គឹម សារូ); មូលដ្ឋានទី ១១៤ (សោ ធឿន); មូលដ្ឋានទី ១១៧ (ផាន់ យឹម); មូលដ្ឋានទី ១៤៤ (លាស់ វណ្ណា); មូលដ្ឋានទី ១៤៥ (ព្រាប ខេន); មូលដ្ឋានទី ១៤៦, ១៥៣ (កែម កួន); មូលដ្ឋានទី ៣២ (ត្រិះ អ៊ាល)។

[28] *សូមមើល* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋានទី ៣២ (iv)។ *សូមមើលផងដែរ* មូលដ្ឋានទី ៣៥។

[29] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋានទី ៣៤។

[30] *សូមមើល* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋានទី ១១, ២៨, និង ២៩។

ហេតុនៃការស្តាប់ចម្លើយ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់ជនរងគ្រោះអំពីផលប៉ះពាល់លើរូបគាត់ផងដែរ។

17. មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងកំហុសស្រដៀងៗគ្នាទាក់ទងនឹងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលដំបូងនូវសក្ខីកម្មរបស់ជនរងគ្រោះអំពីផលប៉ះពាល់លើរូបគាត់[31] ការទទួលយក និងការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយជំនួសសក្ខីកម្មផ្ទាល់មាត់[32] និងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយដោយពុំបានសួរដេញដោល[33]។ ពួកគេក៏ចោទប្រកាន់អំពីកំហុសទាក់ទងនឹងនិយមន័យ និងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ជាពិសេស អត្ថិភាពនៃទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមនៅក្នុងឆ្នាំ ១៩៧៥[34] និងការកំណត់បទល្មើសនៃហេតុការណ៍នៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ទួលពោធិ៍ជ្រៃ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[35]។

18. សហមេធាវីនាំមុខសន្និដ្ឋានថា ការចោទប្រកាន់អំពីកំហុសទាំងនេះ ជាពិសេស ដែលទាក់ទងនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រមទាំង ឧក្រិដ្ឋកម្មចម្បងៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានលើកឡើងដោយជនជាប់ចោទទាំងពីរ មានការជាប់ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដោយសារថា ភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូន ត្រូវបានអង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋាននៃសំអាងហេតុ និងសំអាងច្បាប់នៅក្នុងសាលក្រម[36]។

19. ដោយមិនគិតពីអង្គសេចក្តី គ្រប់បណ្តឹងសាទុក្ខគឺជាដំណាក់កាលថ្មីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែលអាចមានលទ្ធភាពនៃការច្រាលចោទសាលក្រម និង/ឬអាចមានលទ្ធភាពដែលថាភស្តុតាងនឹងត្រូវបានកំណត់បទល្មើសឡើងវិញដោយក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះតុលាការ

[31] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣។

[32] *ដូចខាងលើ* កថាខណ្ឌ ២២។

[33] *ដូចខាងលើ* កថាខណ្ឌ ៥៥។

[34] *ដូចខាងលើ* កថាខណ្ឌ ៤៤។

[35] *ដូចខាងលើ* កថាខណ្ឌ ៩៩-១០០ (ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ) កថាខណ្ឌ ១១២-១១៣ (ទួលពោធិ៍ជ្រៃ), កថាខណ្ឌ ១៣០-១៣១ (ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ)។

[36] *សូមមើល ផងដែរ* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋានទី ១៧២-១៧៥ (ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល), មូលដ្ឋានទី ១៧៩-១៨២ (អំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការជម្លៀសដោយបង្ខំ), មូលដ្ឋានទី ១៨៣-១៨៥ (ការបាត់ខ្លួនដោយបង្ខំ), មូលដ្ឋានទី ១៨៦-១៨៨ (ការប្រព្រឹត្តលើ "ប្រជាជនថ្មី"), មូលដ្ឋានទី ១៩០-១៩៧ (ការធ្វើទុក្ខបុកម្នេញ)។

កំពូល។ ទោះក្នុងករណីណាក៏ដោយ ការមិនអនុញ្ញាតឱ្យភាគីនៃកិច្ចដំណើរការនីតិវិធីមានសិទ្ធិឆ្លើយតបនៅក្នុងដំណាក់កាលនេះ មិនត្រឹមតែប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ប៉ុណ្ណោះនោះទេ វាថែមទាំងប៉ះពាល់ដល់ស្មារតីនៃការចូលរួមរបស់ជនរងគ្រោះដែលមានតែ អ.វ.ត.ក មួយគត់ធ្វើការផ្ដល់ជូននោះ។

## ខ. ដើមបណ្ដឹងរដ្ឋប្បវេណីរក្សាសិទ្ធិក្នុងការដាក់សារណាបញ្ជាក់ពីជំហររបស់ពួកគេចំពោះសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

20. ទោះបីមិនបានប្ដឹងសាទុក្ខទៅលើផ្នែកសម្រេចសេចក្ដីនៃសាលក្រមក៏ដោយ ក៏សហព្រះរាជអាជ្ញាស្នើសុំការបកស្រាយច្បាប់ពាក់ព័ន្ធនឹងការអាចអនុវត្ត សហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ("JCE III") ថាជាទម្រង់មួយនៃការទទួលខុសត្រូវនៅ អ.វ.ត.ក[37]។ សហព្រះរាជអាជ្ញាស្នើសុំការណែនាំផ្លូវច្បាប់ពីអង្គជំនុំជម្រះតុលាការកំពូលលើចំណុចនេះ ដោយបានអះអាងថា "ជាការចាំបាច់ ដើម្បីផ្ដល់ការណែនាំផ្លូវច្បាប់ចំពោះអង្គជំនុំជម្រះសាលាដំបូង ជាពិសេសដោយសារតែវិសាលភាពមានកម្រិតកំណត់នៃបណ្ដឹងសាទុក្ខបន្ទាន់បង្ខំនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៃ អ.វ.ត.ក ព្រោះថា បើសិនជាគ្មានការណែនាំនេះទេ អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទីបី ដោយសារតែគ្មានលទ្ធភាពជាក់ស្ដែងនៃលក្ខខណ្ឌតម្រូវនៃការជូនដំណឹងសមស្រប ចំពោះជនជាប់ចោទ"[38]។

21. សហមេធាវីនាំមុខសូមជូនដំណឹងទៅអង្គជំនុំជម្រះថា ពួកគេរក្សាសិទ្ធិសុំដាក់សារណាដែលបញ្ជាក់ពីគោលជំហររបស់ខ្លួនទៅលើសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដើម្បីតំណាងមតិយោបល់របស់ខ្លួនឱ្យមានប្រសិទ្ធភាពនៅដំណាក់កាលនេះ ក្នុងពេលដែលបញ្ហានេះកំពុងស្ថិតក្នុងការពិចារណាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ នៅឡើយ។

## គ. ការផ្ដល់ថិរវេលាប្រហាក់ប្រហែលគ្នាចំពោះដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងភាគីផ្សេងៗទៀតសម្រាប់រៀបចំចម្លើយតបរបស់ខ្លួនទៅនឹងសារណាបណ្ដឹងសាទុក្ខ គឺជាប្រយោជន៍នៃយុត្តិធម៌

22. សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ ចែងច្បាស់ថា មានរយៈពេល ១០ ថ្ងៃសម្រាប់ដាក់ចម្លើយតបទៅនឹងសារណានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[39]។ ទោះជាយ៉ាងណាក្ដី វិធាន

---

[37] *សូមមើល* សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២ ដល់ ៣ និង ១០។

[38] *ដូចយោងខាងលើ* កថាខណ្ឌ ៩។

[39] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក/វិសោធនកម្មទី ៨ ("សេចក្ដីណែនាំអនុវត្ត") មាត្រា ៨.៣។

៣៩ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យចៅក្រមរៀបចំចិរវេលាសម្រាប់សារណាជាលាយលក្ខណ៍អក្សរ ទាក់ទិននឹងបណ្ដឹងសាទុក្ខ ដោយគិតទៅដល់កាលៈទេសៈនានានៃរឿងក្ដី[40] និងអាចពន្យារពេលបាន ក្រោយពីមានសំណើពីភាគីពាក់ព័ន្ធ[41]។

23. លើសពីនេះទៀត សេចក្ដីណែនាំអនុវត្តតម្រូវថា ពេលវេលាកំណត់ត្រូវរាប់មួយថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក[42]។ ដូចដែលអង្គជំនុំជម្រះបានលើកឡើងរួចមកហើយនៅក្នុងសេចក្ដីសម្រេចពន្យារពេលរបស់ខ្លួន ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ថា "ឯកសារជាភាសាខ្មែរដែលត្រូវដាក់នៅចំពោះមុខ អ.វ.ត.ក គឺជាផ្នែកដ៏សំខាន់នៃកិច្ចដំណើរការនីតិវិធីនៅតុលាការនេះ ព្រោះថា ផ្នែកជាតិ និងផ្នែកអន្តរជាតិនៃស្ថាប័ននីមួយៗ ត្រូវតែបំពេញការងារជាមួយគ្នា [...]"[43]។

24. សហមេធាវីនាំមុខមានកាតព្វកិច្ចធានានូវការរៀបចំការតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឲ្យមានប្រសិទ្ធភាព ក្នុងដំណាក់កាលជំនុំជម្រះ និងក្រោយពេលជំនុំជម្រះ ទន្ទឹមនឹងនោះដែរត្រូវរក្សាតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការចាំបាច់ឲ្យមានការជំនុំជម្រះឆាប់រហ័ស[44]។ សហមេធាវីនាំមុខសូមលើកឡើងថា អនុលោមទៅតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ វាជាប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងប្រយោជន៍នៃការរៀបចំពេលវេលារបស់តុលាការឲ្យមានប្រសិទ្ធផល ដែលត្រូវធ្វើការឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខនានា ក្នុងចិរវេលាដែលបានកំណត់ដោយអង្គជំនុំជម្រះ នៅក្នុងសេចក្ដីសម្រេចពន្យារពេលរបស់ខ្លួន ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤[45]។

25. នៅក្នុងរឿងក្ដីនេះ ជាការសំខាន់ដែលថា ដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងរបស់ពួកគេ មានឱកាសក្នុងការស្វែងយល់ និងបង្កើតយោបល់របស់ខ្លួនទៅលើមូលដ្ឋាននានានៃបណ្ដឹងសាទុក្ខដែលមេធាវីការពារក្ដី និងសហព្រះរាជអាជ្ញា បានលើកឡើង មុនពេលឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ។ ជាការពិតគឺថា មិនត្រឹមតែសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីនឹងមានលើក

[40] វិធានផ្ទៃក្នុង វិធាន ៣៩(២)។

[41] វិធានផ្ទៃក្នុង វិធាន ៣៩(៤)(ក)។

[42] សេចក្ដីណែនាំអនុវត្ត មាត្រា ៧.១ និង ៨.៥។

[43] សេចក្ដីសម្រេចពន្យារពេល ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២១។

[44] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ* (១)។

[45] សេចក្ដីសម្រេចពន្យារពេល ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២៣។

ឡើងនូវទឡ្ហីករណ៍វិភាគលំអិតអំពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុនៅក្នុងសាលក្រមប៉ុណ្ណោះទេ សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក៏នឹងមានការពិភាក្សានានាអំពីច្បាប់អន្តរជាតិ និងទ្រឹស្ដីផងដែរ។

26. សហមេធាវីនាំមុខជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើនលើសលប់ ប្រើប្រាស់ភាសាខ្មែរ និងអាចចូលរួមនៅក្នុងកិច្ចការនេះនៅពេលមានឯកសារជាភាសាខ្មែរ។ សហមេធាវីនាំមុខនឹងអាចធ្វើការពិភាក្សាយ៉ាងមានន័យជាមួយដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងរបស់ពួកគេ តែនៅពេលបានទទួលសារណាបណ្ដឹងសាទុក្ខជាភាសាខ្មែរប៉ុណ្ណោះ។ ប្រសិនបើសំណើនេះមិនត្រូវបានអនុញ្ញាតទេនោះ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងដោយមិនត្រឹមត្រូវ។

27. ទាក់ទិននឹងចំណុចនេះ សហមេធាវីនាំមុខស្នើសុំឱកាសក្នុងការដាក់សារណាតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីរយៈពេល ៣០ ថ្ងៃ ចាប់គិតពីថ្ងៃដាក់សារណានានា បន្ទាប់ពីបានទទួលការជូនដំណឹងពីសំណៅជាភាសាខ្មែរ ដែលត្រូវបានជូនដំណឹងចុងក្រោយគេ។

28. សហមេធាវីនាំមុខលើកឡើងថា ការអនុញ្ញាតតាមសំណើនេះនឹងបង្កើនផលប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងនាមជាភាគីដែលស្មើភាពគ្នានៅក្នុងដំណើរការផ្លូវតុលាការ ដោយមិនឱ្យខាតបង់ពេលវេលា និងការវិនិច្ឆ័យទាន់ពេលវេលាទៅលើបណ្ដឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

## ឃ. ការបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់សារណាឆ្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាការសមហេតុផល ដើម្បីអនុញ្ញាតឱ្យពួកគេមានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ សម្រាប់ការលើកឡើងដែលប្រកបដោយអត្ថន័យ

29. សេចក្ដីណែនាំការអនុវត្តកំណត់ថា ឯកសារដែលដាក់នៅអង្គជំនុំជម្រះតុលាការកំពូលមិនឱ្យលើសពី ៣០ ទំព័រ ជាភាសាអង់គ្លេស ឬបារាំងទេ លើកលែងតែមានការបង្គាប់ផ្សេងពីនេះ[46]។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឱ្យបន្ថែមចំនួនទំព័រកំណត់ដល់មេធាវីការពារក្ដី ដោយសារថា បណ្ដឹងសាទុក្ខរបស់ពួកគេនឹង "មានលក្ខណៈទូលំទូលាយ ដែលតម្រូវឱ្យមានពេលវេលា ចំនួនទំព័រគ្រប់គ្រាន់ សម្រាប់ការលើកឡើងដែលប្រកបដោយអត្ថន័យ"[47]។ ហេតុនេះ ការបន្ថែមចំនួន

[46] សេចក្ដីណែនាំអនុវត្ត មាត្រា ៥.២។

[47] សេចក្ដីសម្រេចពន្យារពេល ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៣។

ទំព័រប្រកបដោយសមាមាត្រភាព ក៏ត្រូវបានផ្តល់ទៅឲ្យសហព្រះរាជអាជ្ញាផងដែរ ក្នុងការដាក់ចម្លើយតបរួមរបស់ខ្លួន[48]។

30. សហមេធាវីនាំមុខនឹងមិនឆ្លើយតបចំពោះមូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយមេធាវីការពារក្តីទេ តែនឹងកំហិតការឆ្លើយតបរបស់ខ្លួនត្រឹមតែមូលដ្ឋានណាដែលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ តាមការវាយតម្លៃជាបឋមទៅលើមូលដ្ឋាននានាក្នុងបណ្តឹងសាទុក្ខដែលត្រូវបានជូនដំណឹងក្នុងសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ពួកគេ មានមូលដ្ឋានជាងមួយរយដែលប៉ះពាល់ដោយផ្ទាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ តាមការប៉ាន់ស្មានត្រួសៗ តួលេខនេះមានប្រហែលមួយភាគបីនៃមូលដ្ឋានសរុបក្នុងបណ្តឹងសាទុក្ខដែលមេធាវីការពារក្តីបានលើកឡើងរួមគ្នា។

31. សហមេធាវីនាំមុខយល់ឃើញថា ក្នុងចំណោមមូលដ្ឋានទាំងនេះ មានមូលដ្ឋានមួយចំនួនដែលត្រួតគ្នានៅក្នុងសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខពីរ និង/ឬ ទាក់ទិនទៅនឹងសេចក្តីសន្និដ្ឋានដូចគ្នានៅក្នុងសាលក្រម[49]។

32. ដោយផ្អែកលើការប៉ាន់ស្មាននេះ សហមេធាវីនាំមុខយល់ថា ការបន្ថែមចំនួន ៦០ ទំព័រទៀតទៅលើចំនួន ៣០ ទំព័រដែលបានអនុញ្ញាត នោះជាការគ្រប់គ្រាន់ហើយ។ ការបង្កើនទំព័រនេះនឹងអនុញ្ញាតឲ្យសហមេធាវីនាំមុខមានចំនួន ៩០ ទំព័រ ក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខពីររបស់មេធាវីការពារដែលសរុបមានចំនួន ៥២០ ទំព័រ។

## ង. ទំហំ និងភាពស្មុគស្មាញនៃសារណាឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់យុត្តិកម្មក្នុងការដាក់ឯកសារមួយភាសាជាមុនសិន ចំណែកសំណៅបកប្រែជាភាសាផ្សេងទៀតនឹងត្រូវដាក់នៅពេលការបកប្រែត្រូវបានបញ្ចប់រួចរាល់ភ្លាម

[48] សេចក្តីសម្រេចពន្យារពេល ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧។ *សូមមើលផងដែរ ដូចយោងខាងលើ* ទំព័រ ១០ (ភាសាអង់គ្លេស) (ដោយចែងថា "សារណាតបរួមរបស់សហព្រះរាជអាជ្ញាមិនត្រូវលើសពី ២៨០ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ហើយមិនមានការកម្រិតលើចំនួនទំព័រសមមូលជាភាសាខ្មែរឡើយ")។

[49] *សូមមើល ឧទាហរណ៍* មូលដ្ឋាននានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់សក្ខីកម្មដែលមានឥទ្ធិពលលើជនរងគ្រោះ៖ សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋាន ៣៤, សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣។ មូលដ្ឋាននានាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋាន ៤២ ដល់ ៤៣។ មូលដ្ឋាននានាដែលពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម៖ សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ នួន ជា មូលដ្ឋាន ១៩៨។

33. មាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្ត អនុញ្ញាតឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យភាគីដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាមុនសិនបាន ក្នុងកាលៈទេសៈពិសេស ឱ្យតែអត្ថបទបកប្រែជាភាសាខ្មែរនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះឱ្យបានលឿនអាចធ្វើទៅបាន។ សហមេធាវីនាំមុខសូមលើកឡើងថា នៅក្នុងរឿងក្ដីនេះ មានកាលៈទេសៈពិសេសដើម្បីផ្ដល់យុត្តិកម្មដល់ការដាក់សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាភាសាអង់គ្លេស ឬជាភាសាបារាំងបាន ដោយសំណៅជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយ។ ស្ថានភាពបច្ចុប្បន្នជាករណីពិសេស ដោយសារថា សារណាឆ្លើយតបសម្រាប់សំណុំរឿង ០០២/០១ នឹងត្រូវបានរៀបចំស្របពេលជាមួយនឹងការត្រៀមរៀបចំសវនាការសម្រាប់សំណុំរឿង ០០២/០២ ហើយតម្រូវឱ្យមានការវិនិច្ឆ័យឱ្យបានទាន់ពេលវេលា។ ដូចបានលើកឡើងខាងលើរួចមកហើយ សារណានឹងមានបញ្ចូលការឆ្លើយតបយ៉ាងក្បោះក្បាយទៅនឹងមូលដ្ឋាននានានៃបណ្ដឹងសាទុក្ខដែលបានលើកឡើងដោយមេធាវីការពារក្ដី ទៅតាមពេលវេលាដែលមានតិចតួចនោះ។

34. ហេតុនេះ សហមេធាវីនាំមុខស្នើសុំអង្គជំនុំជម្រះមេត្តាអនុញ្ញាត អនុលោមតាមមាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្ត ឱ្យដាក់សារណាមួយភាសាជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយ បន្ទាប់ពីការបកប្រែត្រូវបានបញ្ចប់រួចរាល់ភ្លាម។ សហមេធាវីនាំមុខសូមលើកឡើងថា ការអនុញ្ញាតនេះនឹងមិនប៉ះពាល់ដល់ពេលវេលា និងតម្រូវការក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័សនោះទេ។

35. សរុបមក ឱកាសសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី រួមទាំងសហព្រះរាជអាជ្ញាផងនោះ ជាមួយនឹងការពន្យារពេល និងការបន្ថែមចំនួនទំព័រកំណត់ ដោយមានការអនុញ្ញាតឱ្យឆ្លើយតបតែមួយភាសាសិន នឹងមានភាពវិជ្ជមានដល់សិទ្ធិដល់គ្រប់ភាគីទាំងអស់ និងភាពចាំបាច់សម្រាប់កិច្ចដំណើរការនីតិវិធីឆាប់រហ័ស នៅក្នុង បរិបទរបស់ អ.វ.ត.ក តែមួយប៉ុណ្ណោះ។

## IV. សំណើ

**អាស្រ័យហេតុនេះ** ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

(1) **អនុញ្ញាតឱ្យ** សហមេធាវីនាំមុខដាក់សារណាតបរួម ទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីមិនឱ្យលើសពីរយៈពេល ៣០ ថ្ងៃ ក្រោយពេលពួកគេបានទទួលការជូនដំណឹងពីសារណាទាំងនេះជាភាសាខ្មែរ ភាសាអង់គ្លេស ឬភាសាបារាំង។ និង

(2) **ទទួលស្គាល់** ការរក្សាសិទ្ធិរបស់សហមេធាវីនាំមុខ ក្នុងការដាក់សារណាបំភ្លឺពីជំហររបស់ខ្លួនទៅលើសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា មិនឲ្យលើសពីរយៈពេល ៣០ ថ្ងៃ ក្រោយពេលពួកគេបានទទួលការជូនដំណឹងពីសារណាទាំងនេះជាភាសាខ្មែរ ភាសាអង់គ្លេស ឬភាសាបារាំង។

(3) **អនុញ្ញាតឲ្យ** សហមេធាវីនាំមុខបន្ថែមចំនួន ៦០ ទំព័រទៀត សម្រាប់សារណាឆ្លើយតបរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ដោយរាប់ទាំងជើងទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង។ និង

(4) **អនុញ្ញាតឲ្យ** សហមេធាវីនាំមុខអាចដាក់សារណារបស់ខ្លួនមួយភាសាជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយ បន្ទាប់ពីការបកប្រែត្រូវបានបញ្ចប់រួចរាល់ភ្លាម។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

| កាលបរិច្ឆេទ | នាម និងគោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ | **ពេជ អង្គ**<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | **Marie GUIRAUD**<br>សហមេធាវីនាំមុខ | ភ្នំពេញ | |